ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# រាជរដ្ឋាភិបាល

# គោលនយោបាយជាតិ

# ស្តីពី

# ការអភិវឌ្ឍជនជាតិដើមភាគតិច

បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី

ក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០០៩

**រៀបចំដោយក្រសួងអភិវឌ្ឍន៍ជនបទ**

# សេចក្តីផ្តើម

ជនជាតិដើមភាគតិច គឺជាជនជាតិដែលរស់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ហើយជនជាតិទាំងនោះ បង្ហាញនូវឯកភាពជាតិពន្ធុ សង្គម វប្បធម៌ និងសេដ្ឋកិច្ច ប្រតិបត្តិរបៀបរស់នៅតាមប្រពៃណី និងការដាំដុះលើដីដែលខ្លួនកាន់កាប់ទៅតាមក្បួនខ្នាត ទំនៀមទម្លាប់នៃការប្រើប្រាស់ដីជាសមូហភាព។ ការស្រាវជ្រាវបានសន្និដ្ឋានថា នៅក្នុងព្រះរាជាណាចក្រកម្ពុជា មានជនជាតិដើមភាគតិច ដូចជា **ព្នង កួយ ទំពួន ចារាយ គ្រឹង ព្រៅ ការ៉ែត ស្មៀង ក្រោល មិល កាចក់ ព័រ ខោញ ជង សួយ ថ្មូន លុន ស្ទួច រ៉ដែ ខិ រអង ស្តុង ល្មិន ស៉រៃ និងជនជាតិដើមភាគតិចផ្សេងៗទៀត**។ បងប្អូនជនជាតិដើមភាគតិចទាំងអស់ (ប្រមាណជាង១ភាគរយនៃចំនួនប្រជាជនសរុប) រស់នៅក្នុងខេត្តមួយចំនួន ដូចជា **រតនគិរី មណ្ឌលគិរី ក្រចេះ ព្រះវិហារ កំពង់ធំ ស្ទឹងត្រែង ឧត្តរមានជ័យ កំពង់ចាម ពោធិសាត់ កំពង់ស្ពឺ កោះកុង បាត់ដំបង ព្រះសីហនុ បន្ទាយមានជ័យ សៀមរាប និងតំបន់ផ្សេងៗទៀត**។

បងប្អូនជនជាតិដើមភាគតិចទាំងនោះ ប្រកាន់យកវប្បធម៌ ទំនៀមទម្លាប់ ប្រពៃណី ជំនឿ និងភាសាផ្សេងៗគ្នា ទៅតាមក្រុមរបស់ខ្លួន។ ចំណែកឯ មុខរបរសំខាន់សម្រាប់ចិញ្ចឹមជីវិតរបស់ពួកគាត់ គឺការធ្វើកសិកម្មពនេចរតាមលក្ខណៈប្រពៃណី ដោយការកាប់ទន្ទ្រានព្រៃហើយដុត ដើម្បីយកដីធ្វើស្រែចំការវិលជុំ ការប្រមូលអនុផលព្រៃឈើ ការប្រមាញ់ ការនេសាទ និងការចិញ្ចឹមសត្វជាដើម។ ការរស់នៅរបស់ពួកគាត់ពឹងផ្អែកទាំងស្រុងទៅលើបរិស្ថានធម្មជាតិ។ ផ្លូវគមនាគមន៍ និងមធ្យោបាយធ្វើដំណើររបស់បងប្អូនមានការលំបាក និងការខ្វះខាត។ លើផ្នែកសុខភាព បងប្អូនជនជាតិដើមភាគតិចគឺជាជនងាយរងគ្រោះ។ លើផ្នែកអប់រំ ចំណេះដឹងរបស់ពួកគាត់នៅមានកម្រិតទាប។ ហេតុដូច្នេះហើយ ជីវភាពរស់នៅរបស់បងប្អូនក៏នៅមានកម្រិតទាបដែរ។

ដោយពិនិត្យឃើញនូវស្ថានភាពជាក់ស្តែង របស់បងប្អូនជនជាតិដើមភាគតិច ដូចខាងលើនេះ ទើបរដ្ឋាភិបាលសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា និងរដ្ឋកម្ពុជា ក្នុងអំឡុងទសវត្សឆ្នាំ៨០ និងដើមទសវត្សឆ្នាំ៩០ នៃសតវត្សទី២០ បានយកចិត្តទុកដាក់យ៉ាងខ្លាំងដល់ការងារអភិវឌ្ឍជនជាតិដើមភាគតិច ដោយបានបង្កើតឡើងនូវគណៈកម្មាធិការពង្រឹង និងអភិវឌ្ឍភូមិភាគឦសាន ក្នុងបំណងជំរុញការអភិវឌ្ឍលើគ្រប់វិស័យជូនបងប្អូនជនជាតិដើមភាគតិច។ ជាក់ស្តែងវិស័យនានាត្រូវបានជួយជំរុញ និងលើកកម្ពស់គួរឱ្យកត់សម្គាល់ ដូចជា ក្នុងវិស័យអប់រំ រដ្ឋាភិបាលបានផ្តល់អាទិភាពអនុគ្រោះឱ្យសិស្សមកពីភូមិភាគឦសាន ដែលមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ចូលរៀននៅមហាវិទ្យាល័យនានា នៅទីក្រុងភ្នំពេញក្នុងអត្រាមួយសមស្រប។ ជាពិសេស ក្នុងវិស័យថាមពលសំណង់មួយដែលមានចរិតប្រវត្តិសាស្ត្រគឺ សំណង់វារីអគ្គិសនីអូរជុំ ដែលជាប្រភេទវារីអគ្គិសនីធុនមធ្យម អាចផ្តល់អានុភាពជាង ១០០០គីឡូវ៉ាត់ ត្រូវបានចាប់ផ្តើមកសាងឡើងនាខែធ្នូ ឆ្នាំ១៩៩០ និងដាក់ឱ្យដំណើរការនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៩៣ សម្រាប់បម្រើការងារកែច្នៃកៅស៊ូ

ឈើ និងរោងចក្រសិប្បកម្មនានា និងសម្រាប់ឱ្យប្រជាពលរដ្ឋ និងបណ្តាជនជាតិនៅក្នុងទឹកដីរួមខេត្តរតនគិរីប្រើប្រាស់។

បន្ទាប់មក ក្រោយការបោះឆ្នោតជាទូទៅនាឆ្នាំ១៩៩៣ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតឡើងនូវ "គណៈកម្មាធិការអន្តរក្រសួង សម្រាប់ធ្វើការជាមួយកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ ក្នុងការរៀបចំគម្រោងអភិវឌ្ឍន៍ជនជាតិដើមភាគតិច" ដែលមានក្រសួងអភិវឌ្ឍន៍ជនបទជាប្រធាន និងជាភ្នាក់ងារអនុវត្ត និងក្រោយមកទៀតក៏បានបង្កើតឡើងនូវ "នាយកដ្ឋានអភិវឌ្ឍន៍ជនជាតិភាគតិច" ចំណុះឱ្យក្រសួងអភិវឌ្ឍន៍ជនបទ ក្នុងគោលបំណងលើកស្ទួយកម្រិតជីវភាពរស់នៅរបស់បងប្អូនជនជាតិដើមភាគតិច ព្រមទាំងថែរក្សាវប្បធម៌ ប្រពៃណីល្អ ទំនៀមទម្លាប់ និងជំនឿរបស់ពួកគាត់។ ក្នុងកិច្ចខិតខំប្រឹងប្រែងឱ្យសម្រេចគោលបំណងខាងលើ និងដើម្បីឱ្យការអនុវត្តប្រព្រឹត្តទៅមានភាពល្អិតល្អន់សង្វាក់គ្នាលើគ្រប់វិស័យនោះ រាជរដ្ឋាភិបាលក៏បានរៀបចំ ឡើងនូវ "គោលនយោបាយជាតិ ស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិច" នេះ ។

យោងតាមចក្ខុវិស័យយូរអង្វែងរបស់រាជរដ្ឋាភិបាលដែលបានលើកឡើងថា "សម្រេចឱ្យបានកម្ពុជាមួយដែលមានសាមគ្គីភាពសង្គម មានការអប់រំជឿនលឿន និងមានវប្បធម៌ថ្លៃថ្លា ដោយគ្មានភាពក្រីក្រ គ្មានអនក្ខរជននិងគ្មានសុខភាពមិនល្អ "និងផ្អែកលើគោលដៅអភិវឌ្ឍន៍សហស្សវត្សកម្ពុជា ជាពិសេសគោលដៅទី១ "*កាត់បន្ថយភាពក្រីក្រធ្ងន់ធ្ងរនិងភាពអត់ឃ្លាន* " និងគោលដៅទី២ "*សម្រេចឱ្យបានជាទូទៅនូវការអប់រំមូលដ្ឋាន*" នោះ "*គោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិច*" នេះមានគោលដៅដូចខាងក្រោម :

- **ជនជាតិដើមភាគតិចទាំងអស់ ត្រូវមានជីវភាពរស់នៅចាកផុតពីភាពអត់ឃ្លាន និងភាពក្រីក្រធ្ងន់ធ្ងរ។**
- **ជនជាតិដើមភាគតិចទាំងអស់ត្រូវបានផ្តល់ការអប់រំយ៉ាងតិចកម្រិតមូលដ្ឋាន៩ឆ្នាំ និងត្រូវបានផ្តល់សេវាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈសមស្របទៅនឹងតម្រូវការ និងផ្អែកលើទីតាំងភូមិសាស្ត្ររស់នៅរបស់បងប្អូន។**
- **សុខភាពរបស់ជនជាតិដើមភាគតិចត្រូវបានថែទាំឱ្យល្អប្រសើរ។**
- **វប្បធម៌របស់ជនជាតិដើមភាគតិចត្រូវបានការពារ និងថែរក្សាឱ្យមានភាពល្អប្រសើរ។**

ដើម្បីសម្រេចឱ្យបាននូវគោលដៅខាងលើនេះ និងដើម្បីគ្រប់គ្រងការអភិវឌ្ឍឱ្យបានល្អប្រសើរ រាជរដ្ឋាភិបាលមានគោលនយោបាយទូទៅ និងគោលនយោបាយតាមវិស័យសម្រាប់ជនជាតិដើមភាគតិចដែលវិស័យសំខាន់ៗមានជាអាទិ៍ : វិស័យវប្បធម៌ អប់រំ បណ្តុះបណ្តាលវិជ្ជាជីវៈ សុខាភិបាល បរិស្ថាន ដីធ្លី កសិកម្ម ធនធានទឹក ហេដ្ឋារចនាសម្ព័ន្ធ យុត្តិធម៌ ទេសចរណ៍ និងឧស្សាហកម្ម រ៉ែ និងថាមពល។

# ជំពូកទី ១

## គោលនយោបាយទូទៅ

១- ក្រសួង ស្ថាប័នពាក់ព័ន្ធ បង្កលក្ខណៈឱ្យមានការយល់ដឹង និងការគោរពពហុវប្បធម៌ជនជាតិដើមភាគតិច ព្រមទាំងធ្វើយ៉ាងណាឱ្យជនជាតិដើមភាគតិចទាំងនោះទទួលផលប្រយោជន៍ ស្ថិតនៅក្រោមរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ។

២- ជនជាតិដើមភាគតិចទាំងអស់មានសិទ្ធិគោរពវប្បធម៌ ដែលទាក់ទងនឹងជំនឿ ព្រមទាំងទំនៀមទម្លាប់ ប្រពៃណីល្អរបស់ខ្លួន ត្រូវចូលរួមក្នុងដំណើរការអភិវឌ្ឍ និងការថែរក្សាវប្បធម៌ជនជាតិដើមភាគតិច ។ អង្គការ ឬសមាគមតាមមូលដ្ឋានដែលបានបង្កើតឡើងដោយជនជាតិដើមភាគតិចត្រូវបានលើកទឹកចិត្ត ពីសំណាក់រាជរដ្ឋាភិបាលទាំងផ្លូវច្បាប់ និងរដ្ឋបាល ដើម្បីឱ្យបងប្អូនទាំងនោះជួយថែរក្សា ពង្រឹង វប្បធម៌ និងការពារធនធានធម្មជាតិ។ ក្រសួង ស្ថាប័នពាក់ព័ន្ធ ធានាឱ្យបានច្បាស់ថា ជនជាតិដើម ភាគតិចបានចូលរួម និងយល់ច្បាស់ពីអត្ថន័យច្បាប់ ។

៣- ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវពង្រឹង និងគោរពចំណេះដឹង ប្រពៃណីល្អ វប្បធម៌ ការប្រើប្រាស់ដីធ្លី និង ធនធានធម្មជាតិតាមប្រពៃណីរបស់ជនជាតិដើមភាគតិច ដោយផ្អែកតាមច្បាប់រដ្ឋ ដើម្បីធានាការ អភិវឌ្ឍវប្បធម៌ សេដ្ឋកិច្ច និងសង្គមកិច្ចប្រកបដោយនិរន្តរភាពសមស្របតាមកាលៈទេសៈ ។

៤- បទដ្ឋានគតិយុត្តសម្រាប់បង្កើត និងទទួលស្គាល់សមូហភាពប្រជាជន ដូចជាសមាគមមួយ ឬសហគមន៍ មួយថា ជានីតិបុគ្គល ត្រូវបញ្ចូលនូវលក្ខខណ្ឌតម្រូវជាអប្បបរមាមួយចំនួន ដែលចាំបាច់ត្រូវចែងក្នុង លក្ខន្តិកៈរបស់សមាគម ឬសហគមន៍នោះ ដូចជាទម្រង់ដែលនាំដល់ការបង្កើត និងការទទួលស្គាល់ សហគមន៍មួយថាជានីតិបុគ្គល យន្តការតាមដានការអនុវត្តរបស់សហគមន៍ទាក់ទងរវាងគណៈកម្មាធិការ សហគមន៍ (អាជ្ញាធរប្រពៃណី) របស់សហគមន៍ជាមួយអាជ្ញាធររដ្ឋបាលសាធារណៈ សិទ្ធិ និងកាតព្វកិច្ច របស់សហគមន៍ និងសមាជិកភាពរបស់សហគមន៍ជាដើម។ ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងមហាផ្ទៃ ជាស្ថាប័នមានសមត្ថកិច្ចទទួលខុសត្រូវក្នុងការផ្តួចផ្តើមតាក់តែងបទដ្ឋានគតិយុត្តនេះ ។

៥- ជនជាតិដើមភាគតិចដែលប្រកាន់ខ្ជាប់នូវទំនៀមទម្លាប់ ប្រពៃណីល្អ ជំនឿ ភាសាផ្ទាល់របស់ខ្លួន និងការប្រើប្រាស់ធនធានធម្មជាតិ ដូចជាដីធ្លី និងព្រៃឈើតាមលក្ខណៈប្រពៃណីចាំបាច់ត្រូវចងក្រងជា សហគមន៍ ដើម្បីទទួលបានដីជាកម្មសិទ្ធិសមូហភាព ។ ក្រសួងអភិវឌ្ឍន៍ជនបទជាស្ថាប័នមានសមត្ថកិច្ច ក្នុងការកំណត់គោលការណ៍ណែនាំ និងកសាងលក្ខណៈវិនិច្ឆ័យ ស្តីពីការបង្កើតសហគមន៍ជនជាតិដើម ភាគតិច ដោយមានការចូលរួម និងទទួលស្គាល់ពីអាជ្ញាធរដែនដី ក្រសួងមហាផ្ទៃ និងក្រសួង ស្ថាប័នពាក់ព័ន្ធ។

៦- ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ជាស្ថាប័នទទួលខុសត្រូវក្នុងការតាក់តែងបទដ្ឋានគតិយុត្តដើម្បីចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច ។

៧- ក្រសួង ស្ថាប័នពាក់ព័ន្ធ រួមនឹងអាជ្ញាធរខេត្ត ព្រមទាំងសហគមន៍ជនជាតិដើមភាគតិចត្រូវបង្កើតនីតិវិធីសម្រាប់ទទួលស្គាល់ និងកសាងវិធាន ដើម្បីរក្សាសិទ្ធិក្នុងការប្រើប្រាស់ធនធានធម្មជាតិតាមប្រពៃណីរបស់ជនជាតិដើមភាគតិចសមស្របទៅតាមច្បាប់ និងជៀសវាងការកាប់ព្រៃឈើខុសច្បាប់ ក៏ដូចជាការបំផ្លាញបរិស្ថាន។ ត្រូវមានការពិគ្រោះយោបល់ជាមួយជនជាតិដើមភាគតិច ដើម្បីធានាបាននូវផលប្រយោជន៍សេដ្ឋកិច្ច និងការអភិវឌ្ឍនៅក្នុងតំបន់ជនជាតិដើមភាគតិច ។

៨- ការអភិវឌ្ឍធនធានមនុស្សប្រកបដោយនិរន្តរភាព និងសមធម៌ គឺជាមធ្យោបាយដ៏សមស្របមួយដែលត្រូវធ្វើការសិក្សាដើម្បីលើកកម្ពស់ និងថែរក្សាវប្បធម៌ ភាសា និងជំនឿ ព្រមទាំងបរិស្ថានធម្មជាតិរបស់ជនជាតិដើមភាគតិច ។

៩- ក្រសួង ស្ថាប័នពាក់ព័ន្ធ លើកទឹកចិត្តឱ្យជនជាតិដើមភាគតិចចូលរួមក្នុងការបង្កើតគោលនយោបាយគ្រប់ជាន់ថ្នាក់ ការធ្វើផែនការអភិវឌ្ឍ ការត្រួតពិនិត្យ ការវាយតម្លៃ ការការពារទប់ស្កាត់ការកេងប្រវ័ញ្ច អំពើហិង្សា ការមើលងាយ ការរើសអើងគ្រប់រូបភាព ការលើកកម្ពស់សមធម៌យេនឌ័រ ការគ្រប់គ្រង គ្រោះភ័យនៃគ្រោះមហន្តរាយ ការសម្រេចចិត្តស្ដីពីការបង្កើនជីវភាពរស់នៅ និងផលប្រយោជន៍របស់ពួកគាត់ ព្រមទាំងរបស់សហគមន៍។ ជនជាតិដើមភាគតិចមានសិទ្ធិពេញលេញក្នុងការបញ្ចេញមតិយោបល់ និងការសម្រេចចិត្តលើការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងវប្បធម៌របស់ខ្លួនឱ្យមានការរីកចម្រើនទៅតាមសង្គម ។

១០- ក្រសួង ស្ថាប័នពាក់ព័ន្ធ លើកទឹកចិត្តបញ្ចូលវប្បធម៌ ប្រពៃណីល្អ និងការប្រើប្រាស់ភាសាតាមតំបន់របស់ជនជាតិដើមភាគតិច នៅក្នុងកម្មវិធីព័ត៌មាន ទូរទស្សន៍ និងវិទ្យុ។ លើសពីនេះទៀត ជនជាតិដើមភាគតិចមានសិទ្ធិទទួលបានព័ត៌មាន ដែលទាក់ទងនឹងការអភិវឌ្ឍសេដ្ឋកិច្ច សង្គម វប្បធម៌ របស់ខ្លួនព្រមទាំងមានសិទ្ធិចូលរួមកំណត់ការអភិវឌ្ឍនៅក្នុងសហគមន៍របស់ពួកគាត់ ។

១១- ក្រសួង ស្ថាប័នពាក់ព័ន្ធ ចូលរួមលើកកម្ពស់ជីវភាពរស់នៅ និងការចិញ្ចឹមជីវិតរបស់ជនជាតិដើមភាគតិច តាមរយៈការអភិវឌ្ឍលើគ្រប់វិស័យ សមស្របទៅតាមតម្រូវការជាអាទិភាពរបស់បងប្អូនជនជាតិដើមភាគតិច ។

# ជំពូកទី ២

## គោលនយោបាយតាមវិស័យ

### ១. វិស័យវប្បធម៌

១.១- មូលដ្ឋាននៃចំណេះដឹងរបស់ជនជាតិដើមភាគតិច លើទំនៀមទម្លាប់ ប្រពៃណីនៃការប្រើប្រាស់ព្រៃឈើ ដីធ្លី ការប្រកបមុខរបរកសិកម្ម និងប្រព័ន្ធថែរក្សាសុខភាពត្រូវបានសិក្សា ពង្រឹង និងបញ្ចូលក្នុងកម្មវិធីអភិវឌ្ឍន៍។

១.២- តម្លៃវប្បធម៌ ទំនៀមទម្លាប់ ប្រពៃណីល្អ ក៏ដូចជាប្រវត្តិ ភាសា និងជំនឿរបស់ពួកគាត់ ព្រមទាំងការអនុវត្តផ្សេងៗ ត្រូវសិក្សានិងពង្រឹង ដើម្បីធានានូវការអភិវឌ្ឍប្រកបដោយសុវត្ថិភាព និងនិរន្តរភាព ដោយមានការពិគ្រោះយោបល់ និងចូលរួមពីជនជាតិដើមភាគតិច ។

១.៣- បណ្តាអ្នកដឹកនាំសហគមន៍ជនជាតិដើមភាគតិចជាព្រឹទ្ធាចារ្យ ស្ត្រី ក៏ដូចជាបុរស ត្រូវចូលរួមក្នុងការថែរក្សា ការពារ និងអភិវឌ្ឍវប្បធម៌របស់ខ្លួន។

១.៤- កិច្ចការពារវប្បធម៌ជនជាតិដើមភាគតិច គឺស្ថិតនៅក្នុងផលប្រយោជន៍របស់បងប្អូនជនជាតិដើមភាគតិច ក៏ដូចជារាជរដ្ឋាភិបាលដែរ។ ក្រសួង ស្ថាប័នពាក់ព័ន្ធ លើកទឹកចិត្ត និងទទួលស្គាល់អង្គការសមាគមនានាតាមមូលដ្ឋាន និងមជ្ឈមណ្ឌលអភិរក្សវប្បធម៌ ដែលបង្កើតឡើងដោយជនជាតិដើមភាគតិច។

១.៥- ក្រសួង ស្ថាប័នពាក់ព័ន្ធ ជួយបង្កើតសារមន្ទីរ និងមជ្ឈមណ្ឌលវប្បធម៌របស់សហគមន៍ជនជាតិដើមភាគតិច ដោយមានការពិគ្រោះយោបល់ និងឯកភាពពីជនជាតិដើមភាគតិច ដើម្បីសិក្សា និងការពារវប្បធម៌ ដែលក្នុងនោះរួមមាន ទំនៀមទម្លាប់ប្រពៃណីល្អ ភាសា ចំណេះដឹង ទស្សនៈ តម្លៃ ជំនឿ ជីវភាពរស់នៅ សិប្បកម្ម តម្បាញ ស្ថាបត្យកម្ម វាយនភណ្ឌ និងសិល្បៈផ្សេងៗទៀតរបស់ជនជាតិដើមភាគតិច សំដៅផ្តល់ការអប់រំ ចំណេះដឹង បទពិសោធន៍ និងផ្សព្វផ្សាយព័ត៌មានដែលពាក់ព័ន្ធនឹងការអភិវឌ្ឍជនជាតិដើមភាគតិច។

១.៦- ក្រសួង ស្ថាប័នពាក់ព័ន្ធ ធ្វើការសិក្សា ស្រាវជ្រាវ ចងក្រងអំពីវប្បធម៌ ទំនៀមទម្លាប់ ប្រពៃណី ជំនឿរបស់ជនជាតិដើមភាគតិច ដើម្បីបង្កលក្ខណៈឱ្យមានការយល់ដឹង និងគោរពពហុវប្បធម៌ជនជាតិដើមភាគតិចព្រមទាំងធានាឱ្យជនជាតិដើមភាគតិចអាចគោរព និងថែរក្សាវប្បធម៌របស់ខ្លួនប្រកបដោយចីរភាព។ លើសពីនេះទៀតត្រូវមានការចែករំលែកចំណេះដឹងទាំងនេះ ទៅជនជាតិដើមភាគតិចផ្សេងៗទៀត និងប្រជាជនកម្ពុជាទូទៅ។

១.៧- សហគមន៍ជនជាតិដើមភាគតិចមានសិទ្ធិទទួលព័ត៌មានវប្បធម៌ ព័ត៌មានបច្ចេកវិទ្យា ព័ត៌មានសេដ្ឋកិច្ច នយោបាយស្តីពីបញ្ហាទាំងឡាយដែលទាក់ទងនឹងផលប្រយោជន៍របស់ខ្លួន និងមានសិទ្ធិទទួលព័ត៌មានទាក់ទងនឹងជីវភាពរស់នៅប្រកបដោយសមធម៌ និងស្មើភាព។ ជនជាតិដើមភាគតិចមានសិទ្ធិបញ្ចេញមតិ និងចែករំលែកបទពិសោធន៍របស់ខ្លួនផ្តល់ឱ្យរាជរដ្ឋាភិបាល ប្រជាពលរដ្ឋ និងអ្នកដទៃទៀតមកពីប្រទេសនានា។

១.៨- ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវពិនិត្យលទ្ធភាពបង្កើត និងដំឡើងស្ថានីយ៍ផ្សព្វផ្សាយព័ត៌មាន ការអប់រំ និងកម្មវិធីកម្សាន្ត ដូចជាការផ្សព្វផ្សាយអំពីវប្បធម៌ ប្រពៃណីល្អរបស់ជនជាតិដើមភាគតិច ដោយប្រើភាសារបស់ពួកគាត់។

## ២. វិស័យអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

២.១- ការកសាង និងការអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាព និងគុណធម៌ប្រសើរបំផុត លើគ្រប់ផ្នែកដែលឆ្លើយតបទៅនឹងតម្រូវការសង្គម ផលប្រយោជន៍ និងបំណងប្រាថ្នាពិតរបស់ជនជាតិដើមភាគតិចត្រូវចាត់ទុកជាអាទិភាព។

២.២- រដ្ឋរៀបចំឱ្យមានប្រព័ន្ធអប់រំពេញលេញ និងឯកភាពសមស្របទៅតាមតម្រូវការនៃជនជាតិដើមភាគតិច ដើម្បីបង្កើតបាននូវកាលានុវត្តភាពអប់រំមួយសមស្របសម្រាប់កុមារ យុវជន យុវនារី ប្រជាពលរដ្ឋជនជាតិដើមភាគតិច។ រដ្ឋបង្កើនការយកចិត្តទុកដាក់ទៅលើការសិក្សារបស់ជនជាតិដើមភាគតិចតាមរយៈកម្មវិធីសម្ភាររូបវន្ត កំណែទម្រង់កម្មវិធីសិក្សា ដែលមានប្រយោជន៍ដល់សង្គម ផ្តល់អន្តេវាសិកដ្ឋាន អាហារូបករណ៍ ក្នុងការសិក្សាផ្តល់ប្រាក់ឧបត្ថម្ភ និងពង្រាយគ្រូឱ្យទៅបង្រៀននៅកន្លែងខ្វះគ្រូនិងគ្មានគ្រូដើម្បីឱ្យពួកគាត់បានបន្តការសិក្សានៅសាលាមធ្យមសិក្សា សាលាបណ្តុះបណ្តាលវិជ្ជាជីវៈ និងឧត្តមសិក្សា។

២.៣- ការអប់រំក្រៅប្រព័ន្ធ ត្រូវបានរៀបចំឡើង ដោយកម្មវិធីអប់រំមានលក្ខណៈជាអក្ខរកម្ម លេខនព្វន្ត បំណិនជីវិត បំណិនការងារ និងអប់រំកម្រិតមូលដ្ឋានសម្រាប់អ្នកសិក្សា ដែលមិនបានចូលសិក្សានៅគ្រឹះស្ថានសិក្សាក្នុងប្រព័ន្ធ ដើម្បីឱ្យចំណេះដឹង វប្បធម៌ និងភាសា មានការរឹងមាំ និងផ្តល់លទ្ធភាពឱ្យជនជាតិដើមភាគតិចដែលគ្មានជំនាញ អនក្ខរជន និងយុវជនក្រៅសាលា បានក្លាយទៅជាអក្ខរជនវិជ្ជាជីវៈ និងបានអភិវឌ្ឍសមត្ថភាពការងារគ្រប់គ្រងជីវិត និងការបណ្តុះបណ្តាលវិជ្ជាជីវៈ។ សៀវភៅអក្ខរកម្មនឹងត្រូវអភិវឌ្ឍជាពីរភាសា គឺភាសាខ្មែរ និងភាសាជនជាតិដើមភាគតិច យ៉ាងច្រើនត្រឹមថ្នាក់ទី៤ សំដៅផ្តល់ឱកាស ឱ្យបងប្អូនជនជាតិដើមភាគតិចបានចូលរៀនសូត្រ។

២.៤- ការបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវបានអភិវឌ្ឍឡើងសម្រាប់ជនជាតិដើមភាគតិច ជាពិសេសស្ត្រី យុវជន យុវនារី និងមនុស្សពេញវ័យ លើជំនាញមុខរបរសំខាន់ៗដទៃទៀត ដើម្បីឱ្យបងប្អូនមានចំណេះដឹង ចំណេះធ្វើ ឬបំណិន ដែលអាចបំពេញវិជ្ជាជីវៈ ក្រៅពីការដាំដុះ និងការចិញ្ចឹមសត្វ ។

២.៥- កម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនត្រូវបានអភិវឌ្ឍ ដោយជ្រើសរើសបេក្ខជនដែលជាជនជាតិដើមភាគតិច ដើម្បីប្រែក្លាយគាត់ឱ្យទៅជាគ្រូបង្រៀន ដែលអាចបង្រៀនជាពីរភាសាបាន គឺភាសាខ្មែរ និងភាសាជនជាតិដើមភាគតិច ។ គ្រូបង្រៀនចេញពីសាលាបណ្តុះបណ្តាល ត្រូវបានជំរុញ និងលើកទឹកចិត្តឱ្យទៅបម្រើការងារនៅតំបន់ជនជាតិដើមភាគតិចតាមរយៈការឧបត្ថម្ភបន្ថែម និងប្រាក់តំបន់ ។ ការជ្រើសរើសគ្រូត្រូវសមស្របទៅតាមតម្រូវការនៅតាមតំបន់ដាច់ស្រយាល ជាពិសេស ជ្រើសរើសគាត់ចេញពីកន្លែងនោះ ។ កម្មវិធីបណ្តុះបណ្តាលនានា ត្រូវសង្កត់ធ្ងន់លើសារៈសំខាន់នៃចំណេះដឹងតាមប្រពៃណី និងវប្បធម៌ រួមទាំង វិទ្យាសាស្ត្របច្ចេកទេស នៅក្នុងការអភិវឌ្ឍ ក៏ដូចជា ទំនាក់ទំនងរវាងបុរស និងស្ត្រី ព្រមទាំងបំណិនប្រសប់ ក្នុងការដោះស្រាយបញ្ហាផ្សេងៗ ជាភាសាខ្មែរ និងភាសាជនជាតិដើមភាគតិច ។

២.៦- វប្បធម៌ ជំនឿ និងទំនៀមទម្លាប់របស់ជនជាតិដើមភាគតិច ត្រូវបញ្ចូលក្នុងកម្មវិធីសិក្សា ។

២.៧- រដ្ឋបង្កើតមជ្ឈមណ្ឌលសិក្សាសហគមន៍ នៅក្នុងសហគមន៍ជនជាតិដើមភាគតិច សម្រាប់អភិវឌ្ឍសហគមន៍ និងដើម្បីបង្កឱកាសដល់មនុស្សចាស់ និងកុមារជនជាតិដើមភាគតិច ក្នុងការទទួលបានព័ត៌មានអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ ក៏ដូចជា ឱកាសក្នុងការជួបប្រជុំគ្នាជាមួយអ្នកចាស់ទុំ គ្រូដែលបានពង្រាយ និងភ្នាក់ងារអភិវឌ្ឍផ្សេងទៀត ។

២.៨- មជ្ឈមណ្ឌលសិក្សាសហគមន៍ ត្រូវបានបង្កើតឡើងនៅភូមិភាគឦសាន និងតំបន់ដែលមានជនជាតិដើមភាគតិចរស់នៅច្រើន ដើម្បីផលិត និងអភិវឌ្ឍសម្ភារឧបទេសសមស្របនឹងការបង្រៀន និងរៀនដល់ជនជាតិដើមភាគតិច ។ កម្មវិធីសិក្សា និងសម្ភារឧបទេស ស្តីពីការគ្រប់គ្រងធនធាន ឱសថបុរាណ ការអភិវឌ្ឍកសិកម្ម ត្រូវបានអភិវឌ្ឍ ។ រដ្ឋលើកទឹកចិត្ត ជាពិសេសដល់គ្រូបង្រៀន ដើម្បីឱ្យពួកគាត់បំពេញ ការងារបានល្អ ។

## ៣. វិស័យសុខាភិបាល

### ក្រសួង ស្ថាប័នពាក់ព័ន្ធ :

៣.១- លើកទឹកចិត្តក្នុងការលើកកម្ពស់ស្ថានភាពអនាម័យ ការប្រើប្រាស់ទឹកស្អាត និងការផ្សព្វផ្សាយព័ត៌មានដែលអាចឱ្យយល់ដឹងអំពីបញ្ហាសុខភាពទាំងនេះដល់ជនជាតិដើមភាគតិច ។

៣.២- លើកទឹកចិត្តឱ្យមានការសិក្សា និងការប្រើប្រាស់ឱសថបុរាណត្រឹមត្រូវតាមក្បួនខ្នាតក៏ដូចជាការប្រើប្រាស់ឱសថសម័យ ដើម្បីធានាដល់សុខុមាលភាពជនជាតិដើមភាគតិច ។

៣.៣- អនុវត្ត និងពង្រឹងវិធានការ ការពារ ព្យាបាល កាត់បន្ថយជំងឺគ្រុនចាញ់ របេង អេដស៍ អាសន្នរោគ និងជំងឺផ្សេងៗទៀត ដែលមាននៅក្នុងតំបន់ជនជាតិដើមភាគតិចរស់នៅ ជាពិសេស ការចាក់ថ្នាំបង្ការចំពោះកុមារ ស្ត្រីមានផ្ទៃពោះ និងកម្មវិធីផ្តល់អាហារូបត្ថម្ភ ។

៣.៤- លើកទឹកចិត្តការចូលរួមរបស់សហគមន៍ក្នុងការអភិវឌ្ឍ និងការថែទាំសុខភាព ជាពិសេស ចំពោះស្ត្រី និងកុមារ ព្រមទាំងផ្តល់អាទិភាពចំពោះការមិនបង់ថ្លៃសេវាថែទាំសម្រាប់បងប្អូនជនជាតិដើមភាគតិចក្រីក្រ ។

៣.៥- ពង្រឹងផ្នែកសុខភាពដែលទាក់ទងនឹងស្ត្រី មាតា និងទារក ដោយផ្តល់ព័ត៌មានស្តីពីការអប់រំ និងសេវាកម្មចាំបាច់សម្រាប់ស្ត្រី និងគ្រួសារលើបញ្ហាសុខភាពបឋម ជាពិសេស សុខភាពបន្តពូជ ។

៣.៦- អភិវឌ្ឍប្រព័ន្ធសុខាភិបាល ឱ្យបានសមស្របទៅនឹងស្ថានភាពតំបន់ ដែលបងប្អូនជនជាតិដើមភាគតិចរស់នៅដោយបង្កើតប៉ុស្តិ៍សុខភាព មណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែក ដើម្បីផ្តល់សេវាថែទាំសុខភាពព្យាបាល ជូនបងប្អូនជនជាតិដើមភាគតិច ។

៣.៧- ពង្រីកកម្មវិធីបណ្តុះបណ្តាល និងផ្តល់រង្វាន់លើកទឹកចិត្ត ដល់បងប្អូនជនជាតិដើមភាគតិច និងអ្នកស្ម័គ្រចិត្តបម្រើការងារសុខាភិបាល ជូនជនជាតិដើមភាគតិច ដោយរាប់បញ្ចូលទាំងឆ្មបបុរាណផង ។

៣.៨- ផ្តល់ឱកាសពិសេសដល់ជនជាតិដើមភាគតិច ក្នុងការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យសុខាភិបាល ដើម្បីឱ្យពួកគាត់មានលទ្ធភាពចូលរួម និងទទួលបានសេវាសុខាភិបាលសមស្របគ្រប់ពេលវេលា ។

## ៤. វិស័យបរិស្ថាន

៤.១- ក្រសួង ស្ថាប័នពាក់ព័ន្ធ ផ្តល់ការលើកទឹកចិត្តឱ្យបានខ្លាំងក្លាដល់ជនជាតិដើមភាគតិច ក្នុងការផ្លាស់ប្តូរព័ត៌មាន និងចំណេះដឹងទៅវិញទៅមកស្តីពីការគ្រប់គ្រងបរិស្ថាន និងធនធានធម្មជាតិប្រកបដោយចីរភាព ។

៤.២- ជនជាតិដើមភាគតិច ត្រូវចូលរួមការពារ និងទទួលខុសត្រូវចំពោះការថែរក្សាបរិស្ថានធម្មជាតិ និងបរិស្ថាន សង្គមវប្បធម៌ ។ រាល់សិទ្ធិ និងទំនាក់ទំនងក្នុងការចូលរួមទទួលខុសត្រូវ ត្រូវបានការពារដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីធានា និងលើកទឹកចិត្តដល់បងប្អូនជនជាតិដើមភាគតិចចំពោះការប្រើប្រាស់ ការគ្រប់គ្រង និងការថែរក្សាបរិស្ថាន និងធនធានធម្មជាតិ ។

៤.៣- គម្រោងអភិវឌ្ឍន៍ក្នុងតំបន់រស់នៅរបស់ជនជាតិដើមភាគតិច អាចដំណើរការទៅបានលុះត្រាតែមានការវាយតម្លៃលើហេតុប៉ះពាល់បរិស្ថាន និងសង្គម និងមានការផ្សព្វផ្សាយឱ្យសហគមន៍ជនជាតិដើមភាគតិចដែលពាក់ព័ន្ធដឹងជាមុន ដើម្បីឱ្យអ្នកទាំងនោះមានឱកាសចូលរួមផ្តល់មតិយោបល់អំពីតម្រូវការរបស់ពួកគាត់ ។

៤.៤- ក្រសួង ស្ថាប័នពាក់ព័ន្ធ យកចិត្តទុកដាក់បញ្ចូលការអប់រំបរិស្ថានទាំងក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ ដោយប្រើភាសា និងវិធីសាស្ត្រយ៉ាងណាដើម្បីឱ្យជនជាតិដើមភាគតិចងាយយល់ ។

៤.៥- លើកទឹកចិត្តដល់ការសិក្សាស្រាវជ្រាវអំពីជីវៈចម្រុះ និងការប្រើប្រាស់ព្រៃឈើប្រកបដោយនិរន្តរភាព នៅក្នុងសហគមន៍ដែលមានជនជាតិដើមភាគតិចរស់នៅ ដោយត្រូវឱ្យមានការចូលរួមពីជនជាតិដើមភាគតិចផងដែរ ។

៤.៦- ជនជាតិដើមភាគតិចដែលរស់នៅក្នុងតំបន់ការពារធម្មជាតិ និងតំបន់អភិរក្សធនធានធម្មជាតិផ្សេងៗទៀត តាំងពីមុនមកមានសិទ្ធិប្រើប្រាស់ធនធានធម្មជាតិទាំងនេះ តាមលក្ខណៈប្រពៃណីស្របតាមច្បាប់ និងលិខិតបទដ្ឋាននានាដែលនៅមានជាធរមាន ។

## ៥. វិស័យដីធ្លី

៥.១- ក្រសួង ស្ថាប័នពាក់ព័ន្ធ ទទួលស្គាល់ដីដែលសហគមន៍ជនជាតិដើមភាគតិចកំពុងកាន់កាប់ និងប្រើប្រាស់តាមប្រពៃណី រួមមាន ដីទាំងអស់ដែលសហគមន៍បានរៀបចំនិវេសនដ្ឋាន ដីដែលកំពុងប្រើប្រាស់ជាក់ស្តែង សម្រាប់ប្រកបរបរកសិកម្មប្រពៃណី និងដីបម្រុងចាំបាច់ ក្នុងការដូរវេនដំណាំ ដីកប់ខ្មោច ដីព្រៃអារក្ស ដែលត្រូវបានទទួលស្គាល់ដោយអាជ្ញាធររដ្ឋបាល និងអ្នកជិតខាង ។

៥.២- ក្រសួង ស្ថាប័នពាក់ព័ន្ធ ទទួលស្គាល់កម្មសិទ្ធិសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចដែលរួមមាន រាល់សិទ្ធិ និងការការពារកម្មសិទ្ធិ ដូចកម្មសិទ្ធិឯកជនដែរ ។ ប៉ុន្តែសហគមន៍គ្មានសិទ្ធិចាត់ចែងនូវចំណែកណាមួយនៃកម្មសិទ្ធិសមូហភាព ដែលជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋឱ្យទៅបុគ្គលឬក្រុមណាមួយបានឡើយ ។ ការអនុវត្តសិទ្ធិជាកម្មសិទ្ធិទាក់ទងនឹងអចលនវត្ថុរបស់សហគមន៍ និងលក្ខខណ្ឌជាក់លាក់ នៃការប្រើប្រាស់ដីត្រូវស្ថិតនៅក្រោមការទទួលខុសត្រូវរបស់គណៈកម្មាធិការសហគមន៍ និងយន្តការនៃការធ្វើសេចក្តីសម្រេចចិត្តរបស់សហគមន៍ អនុលោមតាមទំនៀមទម្លាប់ និងតាមលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់ពួកគាត់ ហើយត្រូវដាក់ឱ្យនៅក្រោមច្បាប់ទូទៅទាក់ទងនឹងអចលនវត្ថុ ។

៥.៣- ការធ្វើផែនការប្រើប្រាស់ដី ត្រូវមានការចូលរួមពីសំណាក់សហគមន៍ ដើម្បីធានាបាននូវប្រសិទ្ធភាពក្នុងការប្រើប្រាស់ដី ។ គណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត អាជ្ញាធរកាន់កាប់ដីរដ្ឋដែលមានការពាក់ព័ន្ធ ក្រុមប្រឹក្សាឃុំ និងគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ ត្រូវត្រួតពិនិត្យការប្រើប្រាស់ដីធ្លី និងជួយបង្កើតនូវវិធានការដើម្បីធានាការប្រើប្រាស់ធនធានធម្មជាតិឱ្យប្រកបដោយចីរភាព ។

៥.៤- ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាដើម្បីការពារសិទ្ធិជាកម្មសិទ្ធិសមូហភាព និងការអនុវត្តផែនការប្រើប្រាស់ដីនឹងត្រូវផ្សព្វផ្សាយទាំងស្រុងតាមវិធីសាស្ត្រងាយយល់ និងបែបផែនដែលសមាជិកទាំងអស់ក្នុងសហគមន៍ជនជាតិដើមភាគតិចអាចយល់បាន។

៥.៥- ទំនាស់ដីធ្លីដែលកើតមានឡើងក្នុងរង្វង់សហគមន៍មួយ ត្រូវដោះស្រាយដោយគណៈកម្មាធិការសហគមន៍ និងយន្តការនៃការធ្វើសេចក្តីសម្រេចចិត្តរបស់សហគមន៍។ ឯទំនាស់ដីធ្លីដែលកើតមានរវាងសហគមន៍មួយនិងសហគមន៍មួយឬអ្នកជិតខាងឬបុគ្គលដទៃទៀត ត្រូវអនុវត្តតាមគោលការណ៍ និងនីតិវិធីដែលមានចែងក្នុងអនុក្រឹត្យ ស្តីពីគណៈកម្មាធិការសុរិយោដី និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

៥.៦- ជនជាតិដើមភាគតិច ដែលជាសមាជិកសហគមន៍ឬមិនមែនជាសមាជិកក៏ដោយត្រូវបានរាជរដ្ឋាភិបាលការពារទល់នឹងការរំលោភលើទំនៀមទម្លាប់ ឬការយកប្រៀបលើភាពខ្វះការយល់ដឹង ក្នុងការធានាសិទ្ធិកាន់កាប់ឬការប្រើប្រាស់ដីរបស់បងប្អូនឱ្យមានប្រសិទ្ធភាព។

៥.៧- ដីធ្លីរបស់សហគមន៍ជនជាតិដើមភាគតិចដែលជាកម្មសិទ្ធិសមូហភាព មិនអាចលក់ ឬផ្ទេរទៅឱ្យជនឬក្រុមណាមួយដែលនៅក្រៅសហគមន៍បានឡើយ។ ដើម្បីសម្រួលដល់ការវិវត្តសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៃសមាជិកសហគមន៍ជនជាតិដើមភាគតិច និងដើម្បីអនុញ្ញាតឱ្យពួកគាត់បានចេញដោយសេរីពីសហគមន៍ សិទ្ធិនៃកម្មសិទ្ធិឯកត្តជនអាចនឹងត្រូវផ្ទេរជាពិសេសឱ្យពួកគាត់បានលើចំណែកដីសមស្របមួយនៃដីឯកជនរបស់រដ្ឋដែលប្រើប្រាស់ដោយសហគមន៍។

៥.៨- សហគមន៍ជនជាតិដើមភាគតិចមិនអាចប្តូរ ឬត្រូវបានបង្ខំឱ្យប្តូរចេញពីដីដែលខ្លួនបាន និងកំពុងកាន់កាប់ និងប្រើប្រាស់ជាកម្មសិទ្ធិសមូហភាពឡើយ។ ទោះជាយ៉ាងណាក៏ដោយ នៅទីណាដែលត្រូវផ្លាស់ប្តូរទីកន្លែងដោយខានមិនបាន ដែលជាវិធានការលើកលែងសម្រាប់ជាតិ សម្រាប់ជាតម្រូវការនៃផលប្រយោជន៍ជាតិ ឬតម្រូវការជាបន្ទាន់របស់ជាតិ ការផ្លាស់ប្តូរនេះអាចធ្វើទៅបានដោយអនុវត្តតាមបទដ្ឋានស្តីពីការតាំងលំនៅជាថ្មី និងមានសំណងជាមុនបានសមរម្យ និងយុត្តិធម៌។

## ៦. វិស័យកសិកម្ម និងធនធានទឹក

៦.១- រាជរដ្ឋាភិបាលទទួលស្គាល់ទំនៀមទម្លាប់ធ្វើកសិកម្មប្រពៃណី ក៏ដូចជាការប្រមូលផលពីធនធានធម្មជាតិផ្សេងៗរបស់បងប្អូនជនជាតិដើមភាគតិច។ ជាមួយនោះរាជរដ្ឋាភិបាលមានគោលនយោបាយលើកកម្ពស់ជីវភាពរបស់បងប្អូនជនជាតិដើមភាគតិចតាមការអភិវឌ្ឍផ្នែកផលិតកម្មកសិកម្ម ដើម្បីសន្តិសុខស្បៀងបង្កើនគុណភាពអាហារូបត្ថម្ភ និងចំណូលគ្រួសារ។

៦.២- គោលនយោបាយ និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល សម្រាប់វិស័យកសិកម្មក៏ត្រូវប្រើប្រាស់ ដើម្បីអភិវឌ្ឍន៍តំបន់ជនជាតិដើមភាគតិច ដោយសម្របសម្រួលគោរពប្រពៃណីល្អៗ និងអាចកែលំអបណ្តើរៗ នូវទំនៀមទម្លាប់មិនល្អរបស់បងប្អូនជនជាតិដើមភាគតិច ។

៦.៣- ក្រសួង ស្ថាប័នពាក់ព័ន្ធ :

- ត្រូវជំរុញអភិវឌ្ឍន៍វិស័យកសិកម្មតំបន់នោះ តាមផែនការយុទ្ធសាស្ត្រនៃវិស័យ ដោយមានការយកចិត្តទុកដាក់ពិសេស លើទំនៀមទម្លាប់ ប្រពៃណីជនជាតិដើមភាគតិច ។
- ត្រូវព្យាយាមកែទម្លាប់មិនល្អរបស់ជនជាតិដើមភាគតិចក្នុងវិស័យកសិកម្ម (ដាំដុះ ចិញ្ចឹមសត្វ) ជាមួយ នឹងការបញ្ចូលបច្ចេកទេសជឿនលឿនបណ្តើរៗ ។
- ត្រូវរៀបចំជាសហគមន៍របស់ជនជាតិដើមភាគតិចដើម្បីគ្រប់គ្រង និងប្រមូលផលពីធនធានធម្មជាតិ (ព្រៃឈើ សត្វព្រៃ ជលផល...) នៅក្នុងដែនកំណត់របស់សហគមន៍ ដើម្បីធានាបាននូវចីរភាពធនធានធម្មជាតិ និងការការពារបរិស្ថាន ។
- ត្រូវកសាងហេដ្ឋារចនាសម្ព័ន្ធចាំបាច់ សិក្សាស្រាវជ្រាវអំពីសក្តានុពលធនធាន លក្ខខណ្ឌភូមិសាស្ត្រ ធាតុអាកាស ដើម្បីជាមូលដ្ឋានក្នុងការកសាងកម្មវិធីអភិវឌ្ឍន៍វិស័យកសិកម្មរយៈពេលខ្លី មធ្យម និងវែង តាមដែលអាចធ្វើទៅបាន ។
- រៀបចំឱ្យមានឥណទាន និងប្រាក់កម្ចីសម្រាប់ជំរុញការដាំដុះ ចិញ្ចឹមសត្វ ដើម្បីកាត់បន្ថយភាពក្រីក្រ ។
- ត្រូវរៀបចំប្រព័ន្ធធារាសាស្ត្រ ដើម្បីការដាំដុះគ្រប់ប្រភេទ ក្នុងលក្ខណៈដែលការរៀបចំរបៀបរបបដាំដុះអាចប្រមូលផលបាន ។
- ត្រូវជំរុញការបង្កបង្កើតឡើងនូវវារីអគ្គិសនីខ្នាតតូច មធ្យម និងធំ តាមលក្ខណៈភូមិសាស្ត្រដែលអាចធ្វើទៅបាន ព្រោះតំបន់ភូមិភាគឦសាន សុទ្ធសឹងជាតំបន់ខ្ពង់រាប ។
- ត្រូវរៀបចំការផ្គត់ផ្គង់ទឹកស្អាត ដែលពាក់ព័ន្ធនឹងជីវភាព សុខភាពប្រចាំថ្ងៃរបស់ពួកគាត់ ។

## ៧. វិស័យហេដ្ឋារចនាសម្ព័ន្ធ

៧.១- ក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ និងសហគមន៍ ត្រូវយកចិត្តទុកដាក់ក្នុងការស្តារ និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ឱ្យបានប្រសើរជាងមុនក្នុងតំបន់ជនជាតិដើមភាគតិចរស់នៅសំដៅឆ្លើយតបទៅនឹងតម្រូវការផលប្រយោជន៍សេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ និងដើម្បីធានាការធ្វើចរាចរណ៍ក្នុងតំបន់ និងទៅកាន់តំបន់ផ្សេងៗបានងាយស្រួល ។

៧.២- ការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន សេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ និងធនធានធម្មជាតិ ត្រូវអនុវត្ត មុនគម្រោងហេដ្ឋារចនាសម្ព័ន្ធចាប់ផ្តើម ហើយយកលទ្ធផលនៃការសិក្សានោះមកធ្វើការដោះស្រាយ និងផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់សហគមន៍មូលដ្ឋាន ដោយប្រើភាសាខ្មែរ និងប្រែជាភាសាជនជាតិដើមភាគតិច ទៅតាមជនជាតិនីមួយៗ បើអាចធ្វើទៅបាន ។

៧.៣- សហគមន៍ជនជាតិដើមភាគតិច ត្រូវបានផ្តល់ឱកាសឱ្យចូលរួមផ្តល់មតិយោបល់ក្នុងដំណើរការសកម្មភាព របស់គម្រោងហេដ្ឋារចនាសម្ព័ន្ធក្នុងតំបន់ដែលពួកគាត់រស់នៅ ។

៧.៤- អាជ្ញាធរគ្រប់លំដាប់ថ្នាក់ និងជនជាតិដើមភាគតិច ត្រូវធានាថែរក្សា ការពារហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ឱ្យមានប្រសិទ្ធភាពខ្ពស់ ។

## ៨. វិស័យយុត្តិធម៌

៨.១- ស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ច ត្រូវផ្តល់ចំណេះដឹង និងជំរុញការផ្សព្វផ្សាយច្បាប់ និងគោលនយោបាយរបស់រាជរដ្ឋាភិបាលលើវិស័យយុត្តិធម៌ដល់ជនជាតិដើមភាគតិចឱ្យយល់ដឹងអំពី ច្បាប់ សិទ្ធិ និងកាតព្វកិច្ច ក្នុងនាមជាប្រជាពលរដ្ឋរស់នៅក្នុងសង្គម ។

៨.២- គណៈកម្មាធិការសហគមន៍ ដែលជាយន្តការមួយសម្រាប់សម្រុះសម្រួលទំនាស់នៅតំបន់ដែលបងប្អូនជនជាតិដើមភាគតិចរស់នៅត្រូវបានទទួលស្គាល់ និងលើកទឹកចិត្តអោយចូលរួមក្នុងការបម្រើលើវិស័យយុត្តិធម៌ ។ ក្នុងករណីដែលមានជម្លោះលើសពីសមត្ថភាពមិនអាចសម្រុះសម្រួលបាន គណៈកម្មាធិការត្រូវបញ្ជូនករណីនេះ ទៅយន្តការដោះស្រាយជម្លោះផ្សេងៗទៀត ឬទៅតុលាការ ។

៨.៣- គណៈកម្មាធិការសហគមន៍ត្រូវទទួលខុសត្រូវសម្រុះសម្រួលជម្លោះនានា ដែលកើតមានឡើងរវាងសហគមន៍ និងសហគមន៍ បងប្អូនជនជាតិដើមភាគតិច ។ ក្នុងករណីមិនអាចសម្រុះសម្រួលបាន គណៈកម្មាធិការសហគមន៍ ត្រូវបញ្ជូនករណីជម្លោះនេះ ទៅយន្តការដោះស្រាយជម្លោះផ្សេងៗទៀត ឬទៅតុលាការ ។

៨.៤- បើជម្លោះរបស់បងប្អូនជនជាតិដើមភាគតិច ត្រូវដោះស្រាយនៅក្នុងតុលាការ ហើយក្នុងករណីដែលគាត់មិនអាចនិយាយភាសាខ្មែរបាន ស្ថាប័នមានសមត្ថកិច្ចត្រូវតែរកអ្នកបកប្រែជាភាសាជនជាតិដើមភាគតិចមកបកប្រែជូនគាត់ ដើម្បីឱ្យពួកគាត់មានឱកាសយល់ច្បាស់ពីអ្វីដែលនឹងកើតមានឡើងនៅចំពោះមុខតុលាការ ។

## ៩. វិស័យទេសចរណ៍

៩.១- រាជរដ្ឋាភិបាលកម្ពុជាបានកំណត់ច្បាស់ថា វិស័យទេសចរណ៍កម្ពុជា ជាទេសចរណ៍វប្បធម៌ និងធម្មជាតិ។ ការអភិវឌ្ឍទេសចរណ៍នៅតាមតំបន់ជនជាតិដើមភាគតិច ត្រូវធានាការពារវប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ និងផលប្រយោជន៍ជនជាតិដើមភាគតិច រួមទាំងការពារបរិស្ថាន។

៩.២- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍ តាមតំបន់សហគមន៍ជនជាតិដើមភាគតិច ត្រូវរៀបចំឡើងដោយមានការចូលរួមពីសំណាក់សហគមន៍ និងផ្នែកពាក់ព័ន្ធ ហើយផែនការយុទ្ធសាស្ត្រនេះនឹងត្រូវបញ្ចូលទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យទេសចរណ៍របស់ជាតិ ព្រមទាំងត្រូវធ្វើការអនុវត្តប្រកបដោយប្រសិទ្ធភាព។

៩.៣- ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវយកចិត្តទុកដាក់ និងជំរុញកិច្ចសហប្រតិបត្តិការបន្ថែម ក្នុងការស្តារនិងកសាងហេដ្ឋារចនាសម្ព័ន្ធ គាំទ្រទេសចរណ៍ ដើម្បីផ្សារភ្ជាប់ទីក្រុង ទីប្រជុំជន រមណីយដ្ឋានទេសចរណ៍ ទៅកាន់គោលដៅទេសចរណ៍នានា នៅតាមតំបន់សហគមន៍ជនជាតិដើមភាគតិច និងជំរុញការរៀបចំសម្បទាទេសចរណ៍សមស្រប សម្រាប់ឱ្យទេសចរទៅទស្សនាគោលដៅទេសចរណ៍នៃសហគមន៍ជនជាតិដើមភាគតិច ដើម្បីផ្តល់ឱកាសការងារ ប្រាក់ចំណូលនិងការរួមចំណែកអភិរក្ស និងអភិវឌ្ឍសហគមន៍។

៩.៤- សហគមន៍ទេសចរណ៍ជនជាតិដើមភាគតិច ត្រូវចងក្រងជាក្រុមធ្វើការបណ្តុះបណ្តាលនូវការយល់ដឹងពីវិស័យទេសចរណ៍ របៀបដឹកនាំគ្រប់គ្រងសហគមន៍ទេសចរណ៍ និងឧបត្ថម្ភគាំទ្រឱ្យមានការប្រកបអាជីវកម្ម សេវាកម្មទេសចរណ៍ទាំងខ្នាតតូច មធ្យម របស់សហគមន៍ជនជាតិដើមភាគតិច ដើម្បីចូលរួមចំណែកកាត់បន្ថយភាពក្រីក្រ។

៩.៥- វប្បធម៌ ប្រពៃណី ទំនៀមទម្លាប់របស់ជនជាតិដើមភាគតិច ត្រូវបានថែរក្សាការពារ និងប្រែក្លាយទៅជាផលិតផលទេសចរណ៍ ដើម្បីទាក់ទាញទេសចរឱ្យទៅទស្សនាសហគមន៍ ព្រមទាំងអប់រំ និងលើកទឹកចិត្តជនជាតិដើមភាគតិច ឱ្យចូលរួមក្នុងសេវាកម្មមគ្គុទ្ទេសក៍ទេសចរ សេវាកម្មដឹកជញ្ជូនតាមមធ្យោបាយសាមញ្ញ ដូចជាការប្រើប្រាស់សត្វដំរីជាដើម ជំនួសឱ្យទម្លាប់ការបរបាញ់សត្វ ឬកាប់ព្រៃដែលត្រូវបានហាមឃាត់។

៩.៦- ក្រសួង ស្ថាប័នពាក់ព័ន្ធ លើកទឹកចិត្ត និងផ្តល់ឱកាសឱ្យជនជាតិដើមភាគតិច បានចូលបម្រើការងារក្នុងសហគ្រាសទេសចរណ៍ ទាំងក្នុង និងក្រៅតំបន់ ដែលពួកគាត់រស់នៅដោយគ្មានការរើសអើង។

៩.៧- ក្រសួង ស្ថាប័នពាក់ព័ន្ធ ជួយគាំទ្រ និងលើកស្ទួយការងារសិប្បកម្ម ច្នៃប្រឌិត ការផលិតវត្ថុអនុស្សាវរីយ៍នៅតាមសហគមន៍ជនជាតិដើមភាគតិចជួយស្វែងរកទីផ្សារ និងប្រភពហិរញ្ញវត្ថុពី

សំណាក់ដៃគូរអភិវឌ្ឍន៍ ទាំងក្នុង និងក្រៅប្រទេស អង្គការមិនមែនរដ្ឋាភិបាល ភាគីពាក់ព័ន្ធ និងផ្នែកឯកជន ឬពីសំណាក់ទេសចរ សម្រាប់ជួយដល់សហគមន៍ជនជាតិដើមភាគតិច ។

## ១០. វិស័យឧស្សាហកម្ម រ៉ែ និងថាមពល

១០.១- អភិវឌ្ឍផ្នែកឧស្សាហកម្មធុនតូច មធ្យម និងសិប្បកម្មដោយផ្តោតសំខាន់លើការកែច្នៃធនធានធម្មជាតិ កសិឧស្សាហកម្ម និងផលិតផលសិប្បៈ វប្បធម៌ ដែលមាននៅក្នុងតំបន់ជនជាតិដើមភាគតិច ។

១០.២- ផ្តល់ព័ត៌មាន និងចំណេះដឹងដល់ជនជាតិដើមភាគតិច អំពីកិច្ចដំណើរការផលិតកម្មឧស្សាហកម្មធុនតូច មធ្យម និងសិប្បកម្ម ។

១០.៣- ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវអភិវឌ្ឍមូលដ្ឋានផ្គត់ផ្គង់ទឹកស្អាតនៅក្នុងសហគមន៍ជនជាតិដើមភាគតិច ឱ្យមានលទ្ធភាពទទួលបានទឹកស្អាតប្រើប្រាស់ ។

១០.៤- ការផ្លាស់ប្តូរលំនៅឋានថ្មីរបស់ជនជាតិដើមភាគតិចនៅក្នុងតំបន់សម្បទានធនធានរ៉ែ ត្រូវអនុវត្តតាមច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ និងច្បាប់ភូមិបាលដែលមានជាធរមាន ។

១០.៥- ក្រសួង ស្ថាប័នពាក់ព័ន្ធ ជំរុញ និងលើកទឹកចិត្តឱ្យសម្បទានិក ដែលមានអាជ្ញាប័ណ្ណធនធានរ៉ែកសាងហេដ្ឋារចនាសម្ព័ន្ធនានា ដូចជា សាលារៀន មន្ទីរពេទ្យ មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់វិស័យរ៉ែ នៅក្នុងតំបន់ជនជាតិដើមភាគតិច ។

១០.៦- ផ្តល់ការងារឱ្យបានជាអតិបរមាជូនដល់ជនជាតិដើមភាគតិច និងបណ្តុះបណ្តាលអ្នកមិនទាន់មានបទពិសោធន៍ក្នុងការស្វែងរុករករ៉ែធ្វើអាជីវកម្មរ៉ែឱ្យមានសមត្ថភាព និងជំនាញសមស្របដើម្បីចូលរួមការងារជាមួយសម្បទានិក ដែលមានអាជ្ញាប័ណ្ណធនធានរ៉ែ នៅគ្រប់កម្រិតនៃការងារស្វែងរុករករ៉ែ និងការធ្វើអាជីវកម្មរ៉ែ ។

១០.៧- លើកទឹកចិត្តការសិក្សាអប់រំ ណែនាំ បណ្តុះបណ្តាល និងផ្សព្វផ្សាយអំពីការប្រើប្រាស់ថាមពលអគ្គិសនីគ្រប់ប្រភេទឱ្យមានប្រសិទ្ធភាព និងកាត់បន្ថយការប៉ះពាល់បរិស្ថាន និងសង្គម ក្នុងតំបន់ជនជាតិដើមភាគតិច ដើម្បីធានានូវការអភិវឌ្ឍ ប្រកបដោយសុវត្ថិភាព និងនិរន្តរភាព ។

១០.៨- ក្រសួង ស្ថាប័នពាក់ព័ន្ធ គាំទ្របង្កភាពងាយស្រួល និងជួយលើកទឹកចិត្ត ដល់អ្នកអភិវឌ្ឍប្រភពថាមពលអគ្គិសនីខ្នាតតូច និងមធ្យម ដូចជា ថាមពលកកើតឡើងវិញ រួមមានថាមពលពន្លឺព្រះអាទិត្យ វារីអគ្គិសនីខ្នាតតូច ជីវឥន្ធនៈ ជីវម៉ាស ជីវឧស្ម័ន ជាដើម ។ ជំរុញការដាំដុះរុក្ខជាតិផលិតថាមពលតាមរយៈយន្តការអភិវឌ្ឍស្អាត សម្រាប់តំបន់ជនជាតិដើមភាគតិច ។

១០.៩- ជំរុញសមធម៌ក្នុងការទទួលសេវាកម្មអគ្គិសនី និងខិតខំរក្សាថ្លៃអគ្គិសនីឱ្យបានសមរម្យពីសេវាកម្មអគ្គិសនីឯកជនតូចៗ សម្រាប់ការប្រើប្រាស់ធម្មតាក្នុងជីវភាព សម្រាប់តំបន់ជនជាតិដើមភាគតិច ។

# សេចក្ដីសន្និដ្ឋាន

"គោលនយោបាយជាតិស្ដីពីការអភិវឌ្ឍជនជាតិដើមភាគតិច" ដែលបានរៀបចំនេះ លើកឡើង និងគូសបញ្ជាក់ឱ្យឃើញពីចក្ខុវិស័យ ទិសដៅ គោលនយោបាយ និងសកម្មភាពរបស់រដ្ឋាភិបាល និងរាជរដ្ឋាភិបាលកម្ពុជា ចំពោះជនជាតិដើមភាគតិចក្នុងដំណើរឆ្ពោះទៅរកការអភិវឌ្ឍលើគ្រប់វិស័យក្នុងតំបន់ដែលជនជាតិដើមភាគតិចរស់នៅ សំដៅកាត់បន្ថយភាពក្រីក្រ និងលើកស្ទួយកម្រិតជីវភាពរស់នៅរបស់បងប្អូន ផ្ដល់សេវាអប់រំ និងសុខភាពបងប្អូនឱ្យបានល្អប្រសើរ ព្រមទាំងជួយការពារ និងថែរក្សាវប្បធម៌របស់បងប្អូន។

ដើម្បីឱ្យការអភិវឌ្ឍជនជាតិដើមភាគតិចមាននិរន្តរភាពទាំងក្នុងពេលបច្ចុប្បន្ន និងទៅអនាគតសំដៅឆ្លើយតបបានទៅនឹងទិសដៅដែលបានលើកឡើងខាងលើនោះ គោលនយោបាយទូទៅ និងគោលនយោបាយអភិវឌ្ឍន៍តាមវិស័យ បានផ្ដោតជាសំខាន់ទៅលើវិស័យវប្បធម៌ អប់រំ បណ្ដុះបណ្ដាលវិជ្ជាជីវៈ សុខាភិបាល បរិស្ថាន ដីធ្លី កសិកម្ម ធនធានទឹក ហេដ្ឋារចនាសម្ព័ន្ធ យុត្តិធម៌ ទេសចរណ៍ ឧស្សាហកម្ម រ៉ែ និងថាមពលជាដើម។

ការខិតខំប្រឹងប្រែងអស់ពីលទ្ធភាព របស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍជនជាតិដើមភាគតិចនឹងនាំមកនូវការប្រែប្រួល និងភាពរីកចម្រើនយ៉ាងពិតប្រាកដដល់ជនជាតិដើមភាគតិច នៅក្នុងតំបន់ដែលបងប្អូនរស់នៅ។ ការចូលរួមដ៏សកម្មរបស់ជនជាតិដើមភាគតិច ក្នុងកិច្ចសហការជួយកែលំអសហគមន៍របស់ពួកគាត់នឹងអាចធ្វើឱ្យមានការប្រែប្រួលដ៏ធំធេង។

ក្រសួង ស្ថាប័នពាក់ព័ន្ធ ព្រមទាំងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ត្រូវរួមចំណែកជំរុញ និងអនុវត្តនូវគោលនយោបាយជាតិ ស្ដីពីការអភិវឌ្ឍជនជាតិដើមភាគតិចនេះឱ្យមានប្រសិទ្ធភាពខ្ពស់ និងត្រូវផ្សព្វផ្សាយគោលនយោបាយនេះឱ្យបានទូលំទូលាយជូនប្រជាពលរដ្ឋជាពិសេស ជនជាតិដើមភាគតិច និងដៃគូអភិវឌ្ឍន៍នានាក្នុងគោលបំណងលើកទឹកចិត្ត ឱ្យពួកគាត់មានជំនឿជាក់ក្នុងការចូលរួមការងារអភិវឌ្ឍជនជាតិដើមភាគតិច និងអភិវឌ្ឍជាតិ។

# សន្ទានុក្រម

**ជនជាតិដើមភាគតិច :**

ជាតិពន្ធុដែលរស់នៅក្នុងប្រទេសកម្ពុជាតាំងពីដើមរៀងមក ហើយមានភាសា វប្បធម៌ ទំនៀមទម្លាប់ ប្រពៃណីរបស់ខ្លួនខុសពីជនជាតិខ្មែរដែលជាប្រជាជាតិស្នូល។ ជនជាតិដើមភាគតិចមាន ព្នង កួយ ទំពួន ចារាយ គ្រឹង ព្រៅ កាវ៉ែត ស្មៀង ក្រោល មិល កាចក់ ព័រ ខោញ ជងស្អូយ ថ្មូន លុន ស្ទួច រដែ ខិ រអង ស្តុង ល្មឹន ស់រែ និងជនជាតិដើមភាគតិចផ្សេងទៀត ។ ជនជាតិដើមភាគតិចទាំងនោះមានរបៀបរស់នៅតាមប្រពៃណី និងមានការដាំដុះលើដីដែលខ្លួនបាន កាន់កាប់តាមក្បួនខ្នាត ទំនៀមទម្លាប់ នៃការប្រើប្រាស់ដីជា សមូហភាព។ បងប្អូនជនជាតិដើមភាគតិចទាំងអស់មានប្រមាណមួយ (០១) ភាគរយនៃប្រជាជនសរុប ហើយរួមរស់ជាមួយជាតិពន្ធុខ្មែរប្រកបដោយសុខដុមរមនា ដរាបរៀងមកនៅក្នុងខេត្តមួយចំនួន ដូចជាខេត្តរតនគិរី មណ្ឌលគិរី ក្រចេះ ព្រះវិហារ កំពង់ធំ ស្ទឹងត្រែង ឧត្តរមានជ័យ កំពង់ចាម ពោធិសាត់ កំពង់ស្ពឺ កោះកុង បាត់ដំបង ព្រះសីហនុ បន្ទាយមានជ័យ សៀមរាប និងតំបន់ ផ្សេងទៀត។

**កម្មសិទ្ធិសមូហភាព :** ដីធ្លីដែលជាកម្មសិទ្ធិរួមរបស់សហគមន៍ជនជាតិដើមភាគតិចមួយក្រុម ហើយកម្មសិទ្ធិនេះមិនមែនជាកម្មសិទ្ធិឯកជនដោយឡែកៗរបស់សមាជិកសហគមន៍នោះឡើយ។ សមាជិកសហគមន៍ម្នាក់ៗឬគ្រួសារនីមួយៗនៃសហគមន៍គ្មានសិទ្ធិចាត់ចែងដីជាកម្មសិទ្ធិសមូហភាពនេះទេ។

**ជាតិពន្ធុ** : ក្រុមមនុស្សដែលមានរចនាសម្ព័ន្ធគ្រួសារ សេដ្ឋកិច្ច និងសង្គមដូចគ្នា ហើយមានភាសានិងវប្បធម៌តែមួយរួមគ្នា។

**ដីលំនៅដ្ឋាន** : ដីដែលសមាជិកសហគមន៍ជនជាតិដើមភាគតិចប្រើប្រាស់ដើម្បីសាងសង់ផ្ទះស្នាក់នៅឬរស់នៅជាអចិន្ត្រៃយ៍(និវេសនដ្ឋាន)។

**ដីបំរុងចាំបាច់សម្រាប់ផ្លាស់វេនដំណាំ**

**ឬដីរៀបចំបម្រុងសម្រាប់ចំការពនេចរ**

**ឬដីចំការវិលជុំ** : ដីដែលសហគមន៍ជនជាតិដើមភាគតិចធ្លាប់បានប្រើប្រាស់កន្លងមកជាស្រែឬចំការក្នុងការផ្លាស់វេនដំណាំតាមប្រពៃណី។

**ដីព្រៃអារក្ស** : ទិកន្លែងដែលសហគមន៍ទុកសម្រាប់បូជាឬសែនព្រេនតាមទំនៀមទម្លាប់ប្រពៃណី ។

**ដីព្រៃកប់ខ្មោច** : ទិកន្លែងដែលសហគមន៍ប្រើប្រាស់សម្រាប់បញ្ចុះសពទៅតាមប្រពៃណីរបស់ខ្លួន ។

**ទស្សនាទាន** : ការប្រកាន់យកតាមការយល់ឃើញ ។

**ទេសចរណ៍សហគមន៍** : គោលនយោបាយជាតិដែលរៀបចំឡើងដោយក្រសួងទេសចរណ៍ សម្រាប់យកទៅអនុវត្តក្នុងសហគមន៍ ដើម្បីអភិវឌ្ឍវិស័យទេសចរណ៍ក្នុងគោលបំណងកាត់បន្ថយភាពក្រីក្ររបស់បងប្អូនជនជាតិដើមភាគតិចនៃសហគមន៍នោះ ។

**សហគមន៍ទេសចរណ៍** : សហគមន៍ដែលមានបង្អែកលើវិស័យទេសចរណ៍ ។

**អាជ្ញាធររដ្ឋបាល** : អាជ្ញាធរមូលដ្ឋាននិងអាជ្ញាធរដែលមានអាណត្តិកាន់កាប់ដីរដ្ឋឬធនធានធម្មជាតិរបស់រដ្ឋក្នុងតំបន់នោះ ។

**អាជ្ញាធរប្រពៃណី**
**ឬគណៈកម្មាធិការសហគមន៍**
: ថ្នាក់ដឹកនាំសហគមន៍ដែលត្រូវបានជ្រើសរើសដោយសមាជិកសហគមន៍ទាំងមូលដើម្បីដោះស្រាយបញ្ហាក្នុងសហគមន៍ ។ វាជាយន្តការមួយសម្រាប់សម្រុះសម្រួលទំនាស់ក្នុងសហគមន៍នៅក្រៅរង្វង់តុលាការ ។

**អ្នកជិតខាង** : ប្រជាពលរដ្ឋឬសហគមន៍ទាំងឡាយឬអាជ្ញាធរកាន់កាប់ដីរដ្ឋដែលមានព្រំប្រទល់ដីជាប់នឹងដីរបស់សហគមន៍ដែលបានស្នើសុំចុះបញ្ជីដី ។

<u>កំណត់សំគាល់</u>

ជនជាតិភាគតិច : ក្រុមមនុស្សដែលមានសញ្ជាតិខ្មែរ មានភាសា វប្បធម៌ ទំនៀមទម្លាប់ ប្រពៃណី ដោយឡែកផ្ទាល់ខ្លួនហើយពួកគេរស់នៅក្នុងចំណោម ជនជាតិខ្មែរដែលជាប្រជាជាតិស្នូល ។

ប្រជាជាតិស្នូល: ជាតិពន្ធុខ្មែរដែលមានដើមកំណើត និងរស់នៅលើទឹកដីកម្ពុជា តាំងពីរដើមរៀងមក ហើយមានប្រមាណ ( ៩០ ) ភាគរយ នៃប្រជាជនសរុប ។